# ដំណោះស្រាយការបោះឆ្នោតសម្រាប់ប្រជាជនគ្រប់គ្នា

ថ្មី

## សំណួរដែលគេសួរជាញឹកញាប់អំពី ការបោះឆ្នោតតាមសំបុត្រ

### ហេតុអ្វីមានការផ្លាស់ប្តូរ?

ដើម្បីធ្វើឲ្យបទពិសោធន៍ក្នុងការបោះឆ្នោតរបស់លោកអ្នកមានភាពប្រសើរឡើងថែមទៀត ងាយស្រួលនិងអាចប្រើប្រាស់បាន ។ សន្លឹកឆ្នោតនឹងមានភាពងាយស្រួលក្នុងការអាននិងស្រួលក្នុងការធ្វើជម្រើសបោះឆ្នោតរបស់លោកអ្នក។ ការបោះឆ្នោតសាកល ថ្ងៃទី 6 ខែវិច្ឆិកា ឆ្នាំ 2018 គឺជាការបោះឆ្នោតលើកទីមួយ ដែលអ្នកបោះឆ្នោតនឹងទទួលបាននូវ សម្ភារៈថ្មី នៃការបោះឆ្នោតតាមសំបុត្រ (VBM) របស់ពួកគេ ។




### តើសន្លឹកឆ្នោត VBM ថ្មីមានលក្ខណៈដូចម្តេច?

សន្លឹកឆ្នោត VBM គឺជាប័ណ្ណសន្លឹកឆ្នោតពេញផ្ទៃមុខ ដែលផ្ទុកនូវព័ត៌មានចាំបាច់នានា ដើម្បីធ្វើការបោះឆ្នោត។ អាស្រ័យទៅតាមទំហំនៃការបោះឆ្នោតនិងចំនួននៃការប្រកួតប្រជែង នៅលើសន្លឹកឆ្នោត, កញ្ចប់ VBM អាចនឹងផ្ទុកនូវប័ណ្ណជាច្រើនដែលមានការប្រកួតប្រជែង នៅខាងមុខនិងក្រោយ (មើលគម្រូនៅខាងស្តាំ) ។

បើលោកអ្នកស្នើសុំសម្ភារៈបោះឆ្នោតជាភាសាផ្សេងក្រៅពីភាសាអង់គ្លេស នោះ, លោកអ្នកនឹងទទួលបានសន្លឹកឆ្នោតបោះតាមសំបុត្រ VBM មួយជាភាសាដែលលោកអ្នកបានស្នើសុំ ។

### តើតែមប្រៃសណីយ៍ប៉ុន្មានដែលខ្ញុំត្រូវការដើម្បីផ្ញើសន្លឹកឆ្នោតរបស់ខ្ញុំតាមសេវាប្រៃសនីយ៍សហរដ្ឋ (USPS)?

គ្មានទេ។ តែមត្រូវបានបង់ថ្លៃឲ្យមុនរួចជាស្រេចសំរាប់អ្នកបោះឆ្នោតតាមសំបុត្រទាំងអស់ក្នុងខោនធីLos Angeles ។

### តើខ្ញុំអាចបញ្ជូនត្រឡប់សន្លឹកឆ្នោត VBM របស់ខ្ញុំទៅវិញដោយរបៀបណា?

អ្នកអាចបញ្ជូនត្រឡប់សន្លឹកឆ្នោត VBM របស់អ្នកទៅវិញតាមរយៈ USPS (សេវាប្រៃសនីយ៍សហរដ្ឋ), អ្នកគ្រាន់តែទម្លាក់វាក្នុងប្រអប់សំបុត្រ, មិនតម្រូវឲ្យបិទតែមទេ។ បើអ្នកចង់បញ្ជូនវាដោយផ្ទាល់មកយើងខ្ញុំ អ្នកអាចទម្លាក់វានៅទីកន្លែងទម្លាក់សន្លឹកឆ្នោតឬកន្លែងបោះឆ្នោតណាមួយក៏បាន។ មិនថាអ្នកបញ្ជូនត្រឡប់វាទៅវិញតាមរបៀបណានោះទេ សូមកុំភ្លេចចុះហត្ថលេខានិងកាលបរិច្ឆេទនៅលើស្រោមសំបុត្របញ្ជូនត្រឡប់វិញរបស់អ្នក ។

### តើសន្លឹកឆ្នោត VBM ចាប់ផ្តើមផ្ញើតាមសំបុត្រនៅពេលណា?

យើងខ្ញុំចាប់ផ្តើមផ្ញើរចេញសន្លឹកឆ្នោត VBM 29 ថ្ងៃមុនថ្ងៃបោះឆ្នោត ។ អ្នកបោះឆ្នោតដែលបានចុះឈ្មោះជា VBM អចិន្ត្រៃយ៍ នឹងចាប់ផ្តើមទទួលបានសន្លឹកឆ្នោតរបស់ពួកគេប៉ុន្មានថ្ងៃបន្ទាប់ពីការផ្ញើតាមសំបុត្រ ។ ការស្នើសុំតែមួយដង នឹងត្រូវបានដំណើរការប្រចាំថ្ងៃ ហើយគួរទទួលបានក្នុងរយៈពេលប៉ុន្មានថ្ងៃបន្ទាប់ពីការស្នើសុំ ។ សំរាប់ការបោះឆ្នោតសាកលថ្ងៃទី 6 ខែវិច្ឆិកា ឆ្នាំ 2018, យើងខ្ញុំចាប់ផ្តើមផ្ញើសម្ភារៈនៅថ្ងៃទី 9 ខែតុលា ឆ្នាំ 2018 ។

### តើខ្ញុំត្រូវការអ្វីដើម្បីបំពេញសន្លឹកឆ្នោត VBM ?

សន្លឹកឆ្នោត VBM ត្រូវតែបំពេញដោយប្រើប៊ិចទឹកខ្មៅឬខៀវ ។

### តើស្រោមសំបុត្រ VBM ថ្មីមានលក្ខណៈដូចម្តេច?

ស្រោមសំបុត្រ VBM ដែលចេញដោយការិយាល័យមន្ត្រីចុះបញ្ជីរបស់ខោនធី Los Angeles នឹងនៅតែមាន ត្រានៅលើវាដែលសរសេរថា៖ សំបុត្រការបោះឆ្នោតផ្លូវការដែលអនុញ្ញាតដោយសេវាប្រៃសនីយ៍សហរដ្ឋអាមេរិក។ បន្ថែមពីលើនេះអ្នកនឹងឃើញត្រារបស់ខោនធីនៅលើគ្រប់ស្រោមសំបុត្រ។ សម្រាប់សំណួរឬកង្វល់នានាពាក់ព័ន្ធនឹងVBM សូមទូរស័ព្ទទៅលេខ 1-800-815-2666, ជម្រើស 2 ។

# ដំណោះស្រាយការបោះឆ្នោតសម្រាប់ប្រជាជនគ្រប់គ្នា

ថ្មី

## សំណួរដែលគេសួរជាញឹកញាប់អំពីការបោះឆ្នោតតាមសំបុត្រ

### តើខ្ញុំត្រូវផ្ញើត្រឡប់មកវិញនូវប័ណ្ណសន្លឹកឆ្នោតទាំងអស់ ដើម្បីឲ្យជម្រើសរបស់ខ្ញុំត្រូវបានរាប់ ?

យើងខ្ញុំសូមឲ្យលោកអ្នកផ្ញើមកវិញគ្រប់សន្លឹក។ តែយ៉ាងណាក៏ដោយ, បើលោកអ្នកមិនបានផ្ញើមកវិញប័ណ្ណសន្លឹកឆ្នោតទាំងអស់ទេ ក៏មិនមានផលប៉ះពាល់អ្វីឡើយ។ មន្ត្រីចុះបញ្ជីខោនធី Los Angeles នឹងរាប់តែប័ណ្ណដែលលោកអ្នកផ្ញើមកតែប៉ុណ្ណោះ ។

### តើខ្ញុំគួរធ្វើអ្វី បើខ្ញុំធ្វើឲ្យខូចឬបាត់ប័ណ្ណសន្លឹកឆ្នោត VBM របស់ខ្ញុំ?

បើអ្នកធ្វើឲ្យខូចឬបាត់ប័ណ្ណសន្លឹកឆ្នោតរបស់អ្នកមួយឬច្រើន អ្នកអាចស្នើសុំសម្ភារៈប្តូរថ្មីរហូតដល់ 7 ថ្ងៃមុនដល់ថ្ងៃបោះ ឆ្នោត។ បើការប្តូរថ្មីមួយត្រូវបានស្នើសុំ យើងខ្ញុំនឹងផ្ញើជូនកញ្ចប់ VBM ថ្មីស្រឡាង ។ បើមានរយៈពេលតិចជាង 7 ថ្ងៃមុនថ្ងៃបោះឆ្នោតនោះ សូមទាក់ទងការិយាល័យយើងខ្ញុំតាមរយៈលេខ (800) 815-2666, ជម្រើស 2 ។

### តើខ្ញុំអាចស្នើសុំសន្លឹកឆ្នោត VBM ដោយរបៀបណា?

អ្នកអាចស្នើសុំសន្លឹកឆ្នោត VBM តាមអ៊ីនធឺណិតនៅលើគេហទំព័រ **LAvote.net** ឬដោយបំពេញក្រុបខាងក្រោយនៃកូនសៀវភៅសន្លឹកឆ្នោតគំរូ ហើយបញ្ជូនវាត្រឡប់ទៅការិយាល័យមន្ត្រីចុះបញ្ជីខោនធី Los Angeles វិញ ។

### តើខ្ញុំស្នើសុំសន្លឹកឆ្នោត VBM ជាភាសាផ្សេងពីភាសាអង់គ្លេសដោយរបៀបណា?

សូមទូរស័ព្ទទៅផ្នែកសេវាពហុភាសារបស់មន្ត្រីចុះបញ្ជីរបស់ខោនធី Los Angeles តាមរយៈលេខ (800) 815-2666, ជម្រើស 3 ដើម្បីស្នើសុំសម្ភារៈការបោះឆ្នោតជាភាសាមួយផ្សេងទៀត ។

### តើខ្ញុំគួរធ្វើអ្វីជាមួយនឹងឈុតសម្ភារៈ VBM ដំបូងរបស់ខ្ញុំ បើខ្ញុំបានស្នើសុំឈុតថ្មីហើយនោះ ?

សូមសរសេរ "មោឃៈ"(Void) នៅលើសម្ភារៈចាស់ទាំងអស់ ហើយបោះពួកវាចោល ។

### តើមានអ្វីកើតឡើង បើហត្ថលេខានៅលើស្រោមសំបុត្របញ្ជូនត្រឡប់វិញមិនមាន ឬមិនត្រូវគ្នានឹងហត្ថលេខានៅលើឯកសារតម្កល់?

ការិយាល័យមន្ត្រីចុះបញ្ជីខោនធី Los Angeles នឹងផ្ញើតាមសំបុត្រនូវទម្រង់ពាក្យសម្បថសន្លឹកឆ្នោតដែលមិនទាន់ចុះហត្ថលេខាដើម្បីឲ្យអ្នកបំពេញនិងចុះហត្ថលេខា។ អ្នកនឹងមានពេលរហូតដល់ទៅ 8 ថ្ងៃបន្ទាប់ពីថ្ងៃបោះឆ្នោត ដើម្បីបញ្ជូនត្រឡប់នូវទម្រង់ពាក្យនោះទៅការិយាល័យរបស់យើងខ្ញុំដើម្បីឲ្យសន្លឹកឆ្នោតរបស់អ្នកត្រូវបានគេរាប់ ។

### តើខ្ញុំអាចតាមដានសន្លឹកឆ្នោត VBM បានដែរឬទេ?

បាន ដូចដែលដំណើរការ VBM បច្ចុប្បន្នរបស់យើងខ្ញុំដែរ អ្នកបោះឆ្នោតអាចតាមដានសន្លឹកឆ្នោតរបស់ពួកគេតាមអ៊ិនធើណែតនៅលើគេហទំព័រ LAvote.net ។

### តើខ្ញុំអាចស្វែងយល់បន្ថែមអំពីបទពិសោធន៍ VBM ថ្មីនៅកន្លែងណា?

សូមចូលទៅកាន់ **VSAP.lavote.net** ដើម្បីស្វែងយល់បន្ថែមអំពីការស្រាវជ្រាវ និងការរៀបចំដែលបញ្ចូលទៅក្នុងបទពិសោធន៍ VBM ថ្មីនោះ ។